**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ**

លេខ ៦៣៧ សរណន.កសក

# សារាចរណែនាំ
# ស្តីពី
# វិធានការជំរុញការស្តារឡើងវិញការខូចខាតដោយគ្រោះទឹកជំនន់ ទឹកភ្លៀងរដូវវស្សា ឆ្នាំ ២០១៦

នៅរដូវវស្សាឆ្នាំ២០១៦នេះ មានការរាំងស្ងួតនៅដើមរដូវ ធ្វើឱ្យតំបន់មួយចំនួនខ្វះទឹក តែចាប់ពីពាក់កណ្តាលខែមិថុនា ឆ្នាំ២០១៦ មកក៏មានភ្លៀងធ្លាក់ជាបន្តបន្ទាប់នៅទូទាំងប្រទេស គួបផ្សំនឹងការកែលម្អ និងការអភិវឌ្ឍប្រព័ន្ធប្រឡាយស្រោចស្រពបន្ថែមទៀតនោះ បានធ្វើឱ្យការងារបង្កបង្កើនផលស្រូវរដូវវស្សាមានសន្ទុះលឿនគួរជាទីមោទនៈ ថ្វីត្បិតត្រូវជួបនឹងគ្រោះរាំងស្ងួតក្នុងចន្លោះចាប់ពីពាក់កណ្តាលខែកក្កដា រហូតដល់ដើមខែកញ្ញា ដែលបង្កការប៉ះពាល់ដល់សំណាប សន្ទូង និងស្រូវពង្រោះយ៉ាងច្រើនក៏ដោយ តែពុំបានបង្កឱ្យមានការខូចខាតធ្ងន់ធ្ងរឡើយ។ មកទល់ពេលនេះការស្ទូងនិងព្រោះសម្រេចបានចំនួន២ ៥៩៦ ៩៨៤ហិកតា ស្មើនឹង ១០៤,៨៧% នៃផែនការ ២ ៤៧៤ ៤៤៦ ហិកតាលើសឆ្នាំមុនចំនួន ៤៨ ១៧៨ ហិកតា បើប្រៀបធៀបរយៈពេលដូចគ្នា ក្នុងនោះស្រូវស្រាលបង្កើនរដូវ អនុវត្តបានលើផ្ទៃដីចំនួន ២៨១ ៤៧៥ហិកតា នៃផ្ទៃដីអនុវត្តស្រូវស្រាលសរុប ៦៣២ ០៨០ហិកតា កើនលើសឆ្នាំមុន ៤៧ ៥៥៩ហិកតា ដោយទទួលបានទិន្នផលជាមធ្យម ៤,០៦១ តោន/ហិកតា។ ខេត្តចំនួន២៤ ត្រូវបានបញ្ចប់ការងារដាំដុះដំណាំស្រូវរដូវវស្សាហើយ។ រីឯដំណាំរួមផ្សំ និងដំណាំឧស្សាហកម្មផ្សេងៗទៀតក៏អនុវត្តបានតាមផែនការផងដែរ។

ទន្ទឹមនឹងលទ្ធផលទទួលបានខាងលើ ដំណាំស្រូវរដូវវស្សានៅតាមបណ្តាខេត្តមួយចំនួន ក៏ត្រូវទទួលរងនូវបាតុភូតគ្រោះធម្មជាតិបង្កឡើងដោយទឹកជំនន់ទឹកភ្លៀងជាបន្តបន្ទាប់ពីប៉ែកខាងលើ ដែលគិតត្រឹមថ្ងៃទី២០ ខែតុលា ឆ្នាំ២០១៦ បានបង្កការប៉ះពាល់លើផ្ទៃដីសន្ទូង និងស្រូវពង្រោះចំនួន ១៧ ៥៧១ ហិកតា ក្នុងនោះខូចខាតចំនួន ៣ ១៨៦ ហិកតា។ គ្រោះធម្មជាតិនេះ ក៏នឹងអាចកើតមាននៅពេលដ៏ខ្លីខាងមុខជាយថាហេតុ ដែលយើងមិនអាចមើលរំលងបានឡើយ ជាពិសេសការហក់ឡើងយ៉ាងគំហុក ជាថ្មីទៀតនៃទឹកជំនន់ទឹកភ្លៀងនៅប៉ែកខាងលើ។

ក្នុងគោលបំណងធានាបានសន្តិសុខស្បៀង និងឈានទៅសម្រេចបាននូវគោលនយោបាយជំរុញផលិតកម្មស្រូវនិងការនាំចេញអង្ករបស់រាជរដ្ឋាភិបាល ដើម្បីលើកកម្ពស់កំណើនសេដ្ឋកិច្ចជាតិ និងកាត់បន្ថយគ្រោះមហន្តរាយលើដំណាំកសិកម្ម រួមទាំងការធានាដល់អាយុជីវិតសត្វពាហនៈផងនោះ ពិសេសការទប់ស្កាត់នូវការផ្ទុះជំងឺឆ្លងរាលដាលសត្វនាពេលនេះ និងពេលខាងមុខនោះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

អាស័យដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
ទូរស័ព្ទលេខ: (០២៣) ៧២៦ ១២៨/ ៧២៦ ១២៩ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
N° 200 Preah Norodom Blvd., Sangkat Tonle Basak, Khan Chamkarmon, Phnom Penh, Cambodia.
Phone : (023) 726 128 / 726 129, Fax : (855) 23 - 217 320

សូមធ្វើការណែនាំដល់គ្រប់អង្គភាពបច្ចេកទេសក្រោមឱវាទ និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្តទាំងអស់ ត្រូវយកចិត្តទុកដាក់អនុវត្តនូវវិធានការចាំបាច់ និងបន្ទាន់មួយចំនួនដូចខាងក្រោមៈ

១. ត្រូវតាមដានជាប្រចាំនូវស្ថានភាពឧតុនិយមនិងចាត់មន្ត្រីចុះវាយតម្លៃផលប៉ះពាល់ និងការខូចខាតជាបណ្តើរៗ ដើម្បីទទួលបានតួលេខពិតប្រាកដ ដោយក្តាប់ឲ្យបានទីតាំងនិងស្ថានភាពភូមិសាស្ត្រដែលមានលទ្ធភាពអាចស្តារនូវការខូចខាតបាន។

២. ត្រូវពិនិត្យឡើងវិញនូវសន្និធិស្រូវពូជដែលមានតាមបណ្តាខេត្តនីមួយៗទាំងបរិមាណនិងគុណភាព ហើយត្រូវត្រៀមលក្ខណៈជាស្រេចសម្រាប់កិច្ចអន្តរាគមន៍ស្តារការខូចខាតឡើងវិញនៅពេលខាងមុខតាមស្ថានភាពភូមិសាស្ត្រជាក់ស្តែង។

៣. ត្រូវសិក្សារកទីតាំងនិងលទ្ធភាពក្នុងការរៀបចំធ្វើថ្នាលសំណាបរួម ជាពិសេសថ្នាលដាប៉ុកដើម្បីចែកជូនកសិករធ្វើការដកស្ទូងបានទាន់ពេលវេលា នៅពេលទឹកជំនន់ចាប់ផ្តើមស្រក ដោយត្រូវបំផុសកសិករឲ្យស្តារការខូចខាតនេះ ដោយធ្វើស្រែសន្ទូង ដែលចំណេញទាំងពេលវេលា ទាំងបរិមាណគ្រាប់ពូជ (ប្រើគ្រាប់ពូជតិច) ទទួលបានទិន្នផលខ្ពស់និងទាន់រដូវកាលនៅពេលទឹកស្រកទៅវិញ។

៤. ត្រូវពិនិត្យលទ្ធភាព និងត្រៀមលក្ខណៈផ្តល់ពូជដំណាំផ្សេងទៀត ដូចជា ឪឡឹក ពោត សណ្តែក បន្លែ ដំឡូងជាដើម ដែលត្រូវការទឹកតិចជាងដំណាំស្រូវជូនកសិករនៅមូលដ្ឋានណាដែលទទួលរងការខូច-ខាត ពិសេស តាមភូមិសាស្ត្រដែលមានស្ថានភាពមិនសមស្របនឹងការធ្វើស្រែឡើងវិញ ដើម្បីស្តារ-ការខូចខាត និងធានាបាននូវសន្តិសុខស្បៀងជូនប្រជាកសិករ។

៥. ត្រូវជំរុញការណែនាំដល់បងប្អូនកសិករឲ្យបង្កើនការថែទាំដំណាំស្រូវ ដែលមិនរងការខូចខាតដោយត្រូវកម្ចាត់ស្មៅ បំប៉នដី និងទប់ស្កាត់ពីការបំផ្លាញពីសត្វល្អិតចង្រៃនិងជំងឺផ្សេងៗ។

៦. នៅពេលទឹកចាប់ផ្តើមស្រក ត្រូវចលនាប្រមូលកម្លាំងប្រជាកសិករឲ្យរួបរួមគ្នាធ្វើការជួសជុល ឬលើកភ្លឺឡើងវិញដើម្បីរក្សាទឹកទុកក្នុងស្រែឲ្យបានគត់មត់ ចៀសវាងការកាប់ភ្លឺស្រែដាក់ទ្រូឬលប ដែលបណ្តាលឲ្យបាត់បង់ទឹកអស់ពីស្រែ។

៧. ត្រូវពិនិត្យលទ្ធភាពជាក់ស្តែងនូវតំបន់ដែលមានប្រភពទឹកសម្រាប់ស្រោចស្រព ដើម្បីកំណត់ឲ្យបានច្បាស់ពីទីតាំងនិងផ្ទៃដីដែលអាចធានាបានការស្រោចស្រពនិងស្តារឡើងវិញ។

៨. ត្រូវចុះអប់រំបណ្តុះបណ្តាលបច្ចេកទេសដាំដុះដល់ប្រជាកសិករដើម្បីធានាការបង្កើនទិន្នផលឲ្យបានខ្ពស់ជាអតិបរមា និងមានប្រសិទ្ធភាពសេដ្ឋកិច្ចខ្ពស់។

៩. ត្រូវបំផុសប្រជាកសិករឲ្យជំរុញការអនុវត្តផលិតកម្មផ្សេងៗបន្ថែមទៀត តាមស្ថានភាពជាក់ស្តែងក្នុងមូលដ្ឋាននីមួយៗដូចជាការចិញ្ចឹមសត្វ ការចិញ្ចឹមត្រី និងមុខរបរបង្កើនប្រាក់ចំណូលដ៏ទៃទៀត។

១០. បន្តចុះពិនិត្យ តាមដាន ស្រាវជ្រាវសត្វឈឺ ងាប់ ដើម្បីមានវិធានការសង្គ្រោះ និងវិធានការបសុពេទ្យទាន់ពេលវេលា ប្រកបដោយប្រសិទ្ធភាព។

១១. បន្តអប់រំ ផ្សព្វផ្សាយដល់ប្រជាពលរដ្ឋឱ្យបង្កើនការថែទាំ ផ្តល់ចំណី ទឹក ធ្វើជីវសុវត្ថិភាពសត្វ។ បំបែកសត្វឈឺ ពីសត្វជា ករណីមានផ្ទុះជំងឺ ត្រូវធ្វើការពិនិត្យ និងព្យាបាលបន្ទាន់។ រាយការណ៍ជា

ប្រចាំអំពីផលប៉ះពាល់អាយុជីវិត សុខភាពសត្វ និងអំពីស្ថានភាពជំងឺសត្វជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីមានវិធានការដោះស្រាយ។

១២. ជំរុញ និងផ្សព្វផ្សាយដល់ប្រជាកសិករឱ្យចូលរួមស្តារ និងដាំដំណាំចំណីសត្វឡើងវិញ ត្រៀមពូជស្មៅ ដើម្បីចែកជូនប្រជាកសិករសម្រាប់ដាំក្រោយពេលទឹកស្រក ព្រមទាំងជំរុញ និងលើកទឹកចិត្តប្រជាកសិករចិញ្ចឹមសត្វឡើងវិញ។

១៣. ត្រៀមចាក់ថ្នាំបង្ការជំងឺសត្វនៅតាមតំបន់ដែលចាំបាច់ ចុះពិនិត្យនិងព្យាបាលសត្វឈឺ និងត្រៀមអន្តរាគមន៍ ការពារជំងឺរាលដាលឆ្លងសត្វ។ ករណីចាំបាច់ត្រូវរាយការណ៍តាមបណ្តាញផ្តល់ព័ត៌មានទាន់ហេតុការណ៍ដែលមានទូរស័ព្ទលេខ (០១២) ៨៣៣ ៧៩៥ (០១២) ២១៤ ៩៧០ ឬ១២៨៧ និង ១២៨៩ ដើម្បីមានវិធានការទាន់ពេលវេលា។

ដើម្បីអនុវត្តការងារខាងលើនេះឱ្យមានប្រសិទ្ធភាពខ្ពស់ អង្គភាពថ្នាក់កណ្តាល និងមូលដ្ឋានខេត្ត-ក្រុងគ្រប់ជាន់ថ្នាក់ ត្រូវម្ចាស់ការបន្តយកចិត្តទុកដាក់តាមដានសភាពការណ៍និងជំរុញការងារផលិតកម្មកសិកម្មជាប់ជាប្រចាំព្រមទាំងរួមសហការជាមួយសមត្ថកិច្ចពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍ដើម្បីដោះស្រាយបញ្ហានិងការលំបាកផ្សេងៗជាមួយកសិករ ហើយរាយការណ៍អំពីវឌ្ឍនភាព និងការប្រឈមបានទាន់ពេលវេលា។

ទទួលបានសារាចរណែនាំនេះ គ្រប់អង្គភាពជំនាញពាក់ព័ន្ធក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងគ្រប់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត ត្រូវសហការឱ្យបានល្អជាមួយសមត្ថកិច្ចពាក់ព័ន្ធ អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ អនុវត្តសារាចរណែនាំនេះ ឲ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២១ ខែតុលា ឆ្នាំ២០១៦

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**វេង សាខុន**

**កន្លែងទទួល:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ
- គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- គ្រប់សាលារាជធានី-ខេត្ត
- ថ្នាក់ដឹកនាំក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- គ្រប់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត
- ឯកសារ កាលប្បវត្តិ